# អង្គការសង្គមស៊ីវិល សហព័ន្ធសហជីពជាតិ និងអន្តរជាតិអំពាវនាវ
# ឱ្យមានសកម្មភាពបន្ទាន់ ដើម្បីការពារសុវត្ថិភាពកម្មករវិស័យកាត់ដេរនៅកម្ពុជា

Cambodian Alliance of Trade Unions

Cambodian Center for Human Rights

សិល្បៈខ្មែរអមតៈ

C.T.W.U.F Cambodian Tourism Workers Union Federation

klahaan brave

CamboJA

Federation Union of Labor Influences (FULI)

FTUWKC

Coalition of Apparel & Industrial Union (C-AI)

Labor Rights Supported Union of Khmer Employees of Naga World (L.R.S.U)

Worker's Information Center

PED

CITUFED

equitable cambodia

Center for Business and Law Organization

SAC/D Social Action for Community and Development Organization

Kampagne für Saubere Kleidung

Clean Clothes Campaign Germany

Farmer Association For Peace and Development (FAPD)

IWSAP Initiatives for Workers Solidarity in Asia Pacific

Cambodian Youth Power Union Federation (CYPUF)

Communication and Media Promotion Organization

CENTRAL

Building and Wood Workers Trade Union Federation of Cambodia (BWTUC)

Cambodia Tourism Service Workers Federation

WSM We Social Movements

IDEA

ADHOC

NOVI SINDIKAT

Cambodian Truck Drivers Association (CTDA)

COMFREL

CFSWF

achACT

DCA actalliance

LICADHO

ANROEV Asian Network for the Rights of Occupational and Environmental Victims

Public Eye

Building Community Voices

Sahmakum Teang Tnaut Organization - a Cambodian Urban NGO

INTUFE

BWI • BHI • BTI • IBB • ICM

www.bwint.org

Worker's Information Center

Rural Women's Association for Agroecology (R.W.A.A)

SILAKA

GADC Gender and Development for Cambodia

Khmer Association of Informal Economic (KAI)

Clean Clothes Campaign

CNCD 11.11.11

LABOUR BEHIND THE LABEL

ACV

CSC

Cambodian Industrial Workers Federation (CIWF)

Setem

Transparency International Cambodia

CCIM cambodian center for independent media

Federation Union of Free and Independent

Cambodian Youth Network Association

Business and Human Rights Centre

The Cambodian NGO Committee on CEDAW

NGO-CEDAW

**អង្គការសង្គមស៊ីវិល សហព័ន្ធសហជីពជាតិ និងអន្តរជាតិ អំពាវនាវឱ្យមានសកម្មភាពបន្ទាន់ ដើម្បីការពារសុវត្ថិភាពកម្មករវិស័យកាត់ដេរនៅកម្ពុជា**

យើងខ្ញុំដែលជាអង្គការសង្គមស៊ីវិល សហព័ន្ធសហជីព សមាគម សម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ដ៏គួរឲ្យតក់ស្លុតដែលបានកើតឡើងនៅថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២៦ ក្នុងខេត្តកំពង់ឆ្នាំង និងខេត្តស្វាយរៀង។ យោងតាមប្រភពពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺមានកម្មករកាត់ដេរចំនួនសរុប ៩៣នាក់ បានរងផលប៉ះពាល់ ដែលក្នុងនោះមានអ្នកស្លាប់ចំនួន ១៤នាក់ និងអ្នករងរបួសចំនួន ៧៩នាក់ ដែលភាគច្រើនជាស្ត្រី។

ហេតុការណ៍ដ៏អាក្រក់ទាំងនេះ មិនមែនជាទម្រង់ដាច់ដោយឡែកឡើយ ប៉ុន្តែជាភស្តុតាងនៃបញ្ហាដែលកើតមានឡើងជាបន្តបន្ទាប់ និងប្រកបដោយគ្រោះថ្នាក់ក្នុងការដឹកជញ្ជូនកម្មករ និងការការពារសុវត្ថិភាពកម្មករនៅទូទាំងប្រទេសកម្ពុជា។

ទិន្នន័យផ្លូវការ បានបង្ហាញពីភាពធ្ងន់ធ្ងរនៃវិបត្តិដែលកើតមានឡើង ដោយនៅខេត្តកំពង់ឆ្នាំង តែមួយមានកម្មករសរុប ៥៣នាក់ រងផលប៉ះពាល់ ក្នុងនោះមានអ្នកស្លាប់ ៩នាក់ និងរងរបួស ៤៤នាក់។ ចំណែកនៅខេត្តស្វាយរៀង មានកម្មករ ៤០នាក់បាន រងផលប៉ះពាល់ រួមមានអ្នកស្លាប់ ៥នាក់ និងរងរបួស ៣៥នាក់។ តួលេខទាំងនេះបង្ហាញពីតម្រូវការជាបន្ទាន់សម្រាប់ការកែទម្រង់ប្រព័ន្ធដឹកជញ្ជូនរបស់កម្មករដើម្បីទប់ស្កាត់ហេតុការណ៍ដូចនេះមិនឲ្យកើតឡើងជាថ្មីម្តងទៀត។

រៀងរាល់ថ្ងៃ កម្មករជាច្រើនពាន់នាក់ត្រូវធ្វើដំណើរទៅមកពីគេហដ្ឋានទៅបំពេញការងារនៅតាមបណ្តាររោងចក្រនានា ដោយប្រើយានយន្តដែលមានមនុស្សកកកុញ និងមិនត្រូវបានរចនាឡើងសម្រាប់ដឹកអ្នកដំណើរ។ កម្មករត្រូវបង្ខំឲ្យឈរ ឬអង្គុយក្នុងស្ថានភាពមិនមានសុវត្ថិភាព ដោយគ្មានខ្សែក្រវ៉ាត់សុវត្ថិភាព ឬឧបករណ៍ការពារជាមូលដ្ឋានណាមួយ ដែលធ្វើឱ្យពួកគេប្រឈមមុខនឹងហានិភ័យក្នុងកម្រិតខ្ពស់នៅពេលដែលមានគ្រោះថ្នាក់កើតឡើង។

“ហេតុការណ៍គ្រោះថ្នាក់ទាំងពីរនេះ គឺជាការបាត់បង់ជីវិតដែលអាចបង្ការបាន។ កម្មករកាត់ដេរ មិនគួរត្រូវប្រឈមមុខនឹងហានិភ័យ ដើម្បីទៅដល់កន្លែងធ្វើការរបស់ពួកគេនោះទេ។ ការធ្វើកំណែទម្រង់ជាប្រព័ន្ធ និងបន្ទាន់ ត្រូវការយ៉ាងចាំបាច់ឥឡូវនេះ” នេះបើតាមប្រសាសន៍របស់ លោក ឃុន ថារ៉ូ  អ្នកគ្រប់គ្រងកម្មវិធីការងារ នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅកាត់ថា (សង់ត្រាល់)។

យើងទទួលស្គាល់ការឆ្លើយតបរហ័សទាន់ពេលវេលារបស់រដ្ឋាភិបាល ក្នុងការផ្តល់សេវាការព្យាបាល និងសំណង តាមប្រព័ន្ធបេឡាជាតិសន្តិសុខសង្គម ប.ស.ស.។ ទោះជាយ៉ាងណា ការឆ្លើយតបបន្ទាន់តែមួយមុខ គឺមិនគ្រប់គ្រាន់នោះទេ។ ការបង្ការការបាត់បង់ជីវិតនាពេលអនាគត ត្រូវការដោះស្រាយ និងរកឲ្យឃើញនៃដើមហេតុនៃបញ្ហាក្នុងការដឹកជញ្ជូនគ្មានសុវត្ថិភាព។

ដោយហេតុនេះ យើងអំពាវនាវឲ្យ៖

**រដ្ឋាភិបាលកម្ពុជា**

ត្រូវពង្រឹង និងអនុវត្តយ៉ាងតឹងរឹង ច្បាប់ និងបទបញ្ញត្តពាក់ព័ន្ធនឹងការដឹកជញ្ជូនកម្មករ រួមទាំងការហាមឃាត់ការប្រើប្រាស់យានយន្តមិនមានសុវត្ថិភាព ដោយកំណត់ស្តង់ដារសុវត្ថិភាពច្បាស់លាស់ និងធានាការត្រួតពិនិត្យជាប្រចាំ និងការទទួលខុសត្រូវ។ ការវិនិយោគសាធារណៈបន្ថែមលើប្រព័ន្ធដឹកជញ្ជូនសុវត្ថិភាព ដែលអាចដំណើរការបាន និងមានតម្លៃសមរម្យ សម្រាប់កម្មករនៅទូទាំងប្រទេស។

**និយោជក និងសមាគមនិយោជក**

ត្រូវទទួលខុសត្រូវ ក្នុងការធានាថា កម្មករទាំងអស់អាចទទួលបានសេវាដឹកជញ្ជូនដែលមានសុវត្ថិភាពខ្ពស់ មានទំនុកចិត្ត និងមានសេចក្តីថ្លៃថ្នូរ រួមមានការវិនិយោគលើយានយន្តដែលមានសមត្ថភាព មានបរិក្ខារការពារសុវត្ថិភាពគ្រប់គ្រាន់ និងមានការផ្តល់សេវាដែលមានអាជ្ញាបណ្ណ និងដាក់បញ្ចូលសុវត្ថិភាពដឹកជញ្ជូន ជាផ្នែកមួយសំខាន់នៃកាតព្វកិច្ចនៅកន្លែងការងារ។

**ម៉ាកយីហោអន្តរជាតិ និងអ្នកបញ្ជាទិញ**

ត្រូវទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួន ក្នុងការដោះស្រាយហានិភ័យជាប្រព័ន្ធនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់។ ម្ចាស់ម៉ាកយីហោត្រូវផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការប្តេជ្ញាចិត្តខ្ពស់ ដើម្បីធានាថា រោងចក្រត្រូវវិនិយោគលើការដឹកជញ្ជូនសុវត្ថិភាព និងធានាថា សុវត្ថិភាពកម្មករ ទាំងក្នុង និងក្រៅកន្លែងការងារ គឺជាស្តង់ដារដែលមិនអាចបដិសេធបាន។

សុវត្ថិភាពកម្មករ ត្រូវតែពង្រីកលើសពីច្រកចូលរបស់រោងចក្រ។ មិនមានកម្មករណាម្នាក់គួរត្រូវប្រឈមមុខនឹងហានិភ័យ ឬគ្រោះថ្នាក់ដល់អាយុជីវិត ដើម្បីតែរកចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ និងការរស់នៅដោយសេចក្តីថ្លៃថ្នូរនោះទេ។ ការបាត់បង់ជីវិតកម្មករ ១៥នាក់ គឺជាសោកនាដកម្ម និងមានផលវិបាកធ្ងន់ធ្ងរដល់ក្រុមគ្រួសាររបស់ពួកគេ។ វិធានការសម្រាប់បង្ការក្នុងពេលអនាគត ត្រូវការការទទួលខុសត្រូវរួម កិច្ចសហការសម្របសម្រួល និងការវិនិយោគដែលមានន័យពីគ្រប់ភាគីពាក់ព័ន្ធ។

យើងត្រៀមខ្លួនរួចរាល់ក្នុងការចូលរួមសហការស្ថាបនា ជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាថា កម្មករកាត់ដេរទាំងអស់នៅកម្ពុជា មានលក្ខខណ្ឌការងារ និងការធ្វើដំណើរដែលមានសុវត្ថិភាព និងមានសេក្តីថ្លៃថ្នូរក្នុងនាមជាមនុស្ស។